ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី

ត្រីមាសទី៤ ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ក
ស
វ




E
C
O
S
O
C
C

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
www.ecosocc.gov.kh
info@ecosocc.kh
(855) 012 915 577 (855) 012 912 009

# <u>គតិបណ្ឌិតរដ្ឋបុរសជាតិ</u>

« ទឹកចិត្តដ៏ល្អរបស់គ្រូពេទ្យ និងបុគ្គលិកពេទ្យ
ក៏ជាឱសថដ៏សក្តិសិទ្ធិមួយដែរ។ »

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**

ឆ្នាំ២០០០

# មាតិកា


ទំព័រ

I- បទអត្ថាធិប្បាយ សីលធម៌ ១-៤

II- ការពិនិត្យផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១- សេចក្តីព្រាងច្បាប់ គ្រប់គ្រងទឹកស្អាត ៥

២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ៦

III- បទវិភាគៈ

- ទីលានប្រជែងភូមិសាស្ត្រនយោបាយ ៧-៩

IV- នាទីសិក្សា

- បញ្ហាដែនដីកូសាំងស៊ីន និងបញ្ហាព្រំដែន ១០-១១

V- នាទីវប្បធម៌

១- បច្ចេកសព្ទភូមិវិទ្យាប្រជាជន ១២-១៤

២- ស្វែងយល់ពីបុណ្យកឋិន ឬកឋិនទាន ១៥-១៧

VI- នាទីកំណាព្យ

- កើតជាមនុស្សនេះ (កាកគតិ) ១៨

VII- នាទីកំសាន្ត

- ល្បើកចាបស្រុកនិងចាបព្រៃ ១៩



**ក្រុមការងារព្រឹត្តិបត្រ**

នាយកគ្រប់គ្រង

- យឹម ណុលសន

និពន្ធនាយក

- អ៊ីវ ថុង

ការិយាល័យនិពន្ធ

- នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត
- លី គឹមសុខ
- ឆយ អូន
- ទីប្រឹក្សាបច្ចេកទេស
- សមាជិក-សមាជិកា នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌

អ្នកចាត់ចែងផលិត

- ប៉ិច សុខា
- អ៊ិន តុលា

អ្នកចែកផ្សាយ

- អៀង រដ្ឋា
- សេក វុទ្ធី

ការីកុំព្យូទ័រ

- អេង រត្នមុនី
- សយ វាស្នា
- យឹម ច័ន្ទតារា

# សីលធម៌ ( Morale )

ការរស់នៅរបស់មនុស្សក្នុងសង្គមតំរូវចាំបាច់ឱ្យមនុស្សស្វែងរកគោលការណ៍អ្វីមួយសម្រាប់ការអនុវត្តឱ្យបានប្រសើរជាមួយមនុស្សផងគ្នាក្នុងសង្គម ខ្លះបង្កើតទំនៀមទម្លាប់ ខ្លះបង្កើតជំនឿ ខ្លះស្វែងរកសាសនាជាបង្អែក ក្នុងគោលបំណងរៀបចំការរស់នៅឱ្យបានប្រសើរ មានន័យថាគេស្វែងរកសីលធម៌នេះឯង។

**ក- និយមន័យ**

- តាមន័យទូទៅ សីលធម៌សម្គាល់នូវទ្រឹស្តី និងពាក្យទូន្មានទាំងឡាយណាដែលដឹកនាំទៅរកផ្លូវល្អ និងចៀសវាងផ្លូវអាក្រក់សម្រាប់ការរស់នៅ។
- តាមន័យពិសេស សីលធម៌សម្គាល់ការអប់រំតាមផ្លូវចិត្តឱ្យបានប្រសើរ។

**ខ- នានាភាពនៃសីលធម៌**

ក្នុងការរស់នៅ សីលធម៌មានច្រើនយ៉ាង ដែលយើងនឹងលើកយកមកបង្ហាញដូចតទៅ ៖

**ខ១- សីលធម៌ផ្ទាល់ខ្លួន**

- ដឹងខុសត្រូវ ( conscient du vrai et du faux )
- ស្គាល់ល្អស្គាល់អាក្រក់ ( conscient du bien et du mal )
- តាំងខ្លួនជាម្ចាស់ចិត្តរបស់ខ្លួន ( maitrise de soi )
- ទទួលខុសត្រូវនឹងអំពើរបស់ខ្លួន ( responsable de ses faits )
- ក្លាហានក្នុងផ្លូវត្រូវ ( avoir du courage dans la juste voie )

**ខ២- សីលធម៌ក្នុងគ្រួសារ**

- ម្តាយឪពុកចិញ្ចឹមកូន ដោយពុំនឹកគិតដល់ការសងគុណតបមកវិញ ព្រោះជាមុខងាររបស់ម្តាយ ឪពុក ( rôle des parents )
- ធ្វើឲ្យមានភាពសុខដុម
- ស្រលាញ់កូនស្មើៗគ្នា
- រៀបចំកូនឲ្យបានទៅជាពលរដ្ឋពេញលេញ

**ខ៣- សីលធម៌ក្នុងវិជ្ជាជីវៈ**

- មានមនសិការការងារ ( conscience professionnelle )
- រកស៊ីតាមសមត្ថភាព ( à chacun selon ses capacités )
- រកស៊ីតាមសម្មាជីវោ ( profession juste )
- មិនរំលោភលើអ្នកតូចជាងខ្លួន
- មិនធ្វើការហួសកម្លាំងដែលនាំឱ្យមានជំងឺឥតប្រយោជន៍

**ខ៤- សីលធម៌ក្នុងសង្គម**

- មិនបែកបាក់គ្នា
- មិនមើលងាយមនុស្សផងគ្នា

- ស្រឡាញ់យុត្តិធម៌
- រាប់អានមនុស្សទូទៅ
- ទទួលស្គាល់ទុក្ខវេទនារបស់អ្នកដទៃ
- មិនឈ្លានពានអ្នកដទៃ

**ខ៥- សីលធម៌ក្នុងពិភពលោក**

ការរួមរស់ដោយសន្តិភាពជាមួយប្រទេសដទៃ ( la coexistence pacifique ) ដែលអង្គការសហប្រជាជាតិ ( O N U = U N ) បានប្រជុំគ្នានៅក្រុង បានឌុង នាប្រទេសឥណ្ឌូនេស៊ី។

**គ- សីលធម៌យល់តាមទស្សនៈអ្នកប្រាជ្ញនីមួយៗ**

**គ១- សីលធម៌របស់ សូក្រាត :** ( Socrate ) ទស្សនវិទូក្រិច សតវត្សទី៥ មុនគ.ស.បិតនៅលើការកសាងកុសល ដើម្បីឲ្យបានសម្រេចសុភមង្គល ប៉ុន្តែមិនត្រូវយល់ថាសុភមង្គល បិតនៅលើទ្រព្យសម្បត្តិ អំណាច និងកិត្តិយសជាដាច់ខាត។ ការសប្បាយតាមផ្លូវចិត្តប្រសើរជាង ការសប្បាយនឹងទ្រព្យសម្បត្តិ។ នេះហើយជាគុណធម៌របស់ព្រលឹង ប៉ុន្តែដើម្បីឱ្យមានសីលធម៌និងគុណធម៌ ជាបឋមមនុស្សត្រូវមានពុទ្ធិ ដើម្បីរៀបចំខ្លួនឱ្យបានចេះដឹងសិន ព្រោះអវិជ្ជា ឬភាពល្ងិតល្ងង់ពុំអាចឱ្យមនុស្សយល់តម្លៃសីលធម៌បានទេ ព្រមទាំងជាប្រភពនៃអំពើអាក្រក់ទៀតផង។ សូក្រាតបានអះអាងទៀតថា មនុស្សធ្វើអំពើអាក្រក់ មកពីពុំយល់ថាជាអំពើអាក្រក់ ( Si un homme fait le mal , c ´est parce qu ´ il n ´a pas compris , donc qu ´ il ignore que son action lui sera nuisible )។

បន្ទាប់មកទៀតសូក្រាតអប់រំមនុស្សឲ្យមនុស្សតាំងចិត្តជាម្ចាស់ចិត្តរបស់ខ្លួនដូចជាក្នុងពាក្យទូន្មានមួយឃ្លារបស់គាត់ពោលថា « connais-toi, toi meme » មានន័យថា ត្រូវស្គាល់ខ្លួនឯងសិន។

**គ២- សីលធម៌របស់ប្លាតុង :** ( Platon ) គឺជាសិស្សរបស់សូក្រាត សតវត្សទី៥មុនគ.ស. ដែលជាសីលធម៌មួយបែបប្លែកពីសូក្រាត ប្លាតុងបញ្ជាក់ថា ដើម្បីឱ្យមនុស្សមានសីលធម៌ គេត្រូវដកហូតទ្រព្យសម្បត្តិឯកជនឱ្យអស់ពីបុគ្គល គឺនៅសល់តែមនោ ពេលនោះទើបមនុស្សអាចយល់ពីតម្លៃសីលធម៌ ហើយបើមនុស្សនៅតែមានទ្រព្យ ទ្រព្យនោះនឹងក្លាយទៅជាមាយាបិទបាំងមនុស្សមិនឱ្យមើលឃើញសីលធម៌។សីលធម៌របស់ប្លាតុងគឺយុត្តិធម៌ ហើយដើម្បីស្វែងរកយុត្តិធម៌ មនុស្សត្រូវប្រកបដោយសមត្ថភាព៣ប្រការៈ

- ប្រការទី១ : គឺមនុស្សត្រូវប្រកបដោយវិចារណៈ ដើម្បីស្វែងរកពុទ្ធិ
- ប្រការទី២ : គឺមនុស្សត្រូវមានចិត្ត ដើម្បីធ្វើចិត្តឱ្យមានសេចក្តីក្លាហាន
- ប្រការទី៣ : គឺមនុស្សត្រូវមានចំណូលចិត្ត ប៉ុន្តែពុំត្រូវចង់បានហួសប្រមាណ។

**គ៣.សីលធម៌របស់អារីស្តូត:** ( Aristote ) ទស្សនវិទូក្រិចសតវត្សទី៤មុនគ.ស.បិតនៅត្រង់ការស្វែងរកសុភមង្គលនិងការចេះសប្បាយ ព្រោះបើមនុស្សមិនចេះសប្បាយ មនុស្សនឹងត្រូវបាត់បង់តម្លៃរបស់ខ្លួនជាមនុស្ស ប៉ុន្តែ សុភមង្គលនិងការសប្បាយត្រូវបិតនៅក្នុងផ្លូវត្រូវ ហើយមិនត្រូវសប្បាយដូចសត្វទេ។ សីលធម៌មួយបែបទៀតរបស់អារីស្តូត គឺការអប់រំមនុស្សឲ្យដើរផ្លូវកណ្តាលដូចជាៈ

- កុំក្លាហានពេក តែកុំកំសាកពេក
- កុំចង់បានពេក តែមិនត្រូវមិនរវីរវល់សោះនោះទេ
- កុំគិតប្រយោជន៍ផ្ទាល់ខ្លួន តែក៏មិនត្រូវភ្លេចខ្លួនឯងដែរ។

**គ៤- សីលធម៌របស់ពួកខន្តីនិយម** : (les stoïciens) បិតនៅត្រង់ « រស់នៅតាមធម្មជាតិ » (vivre selon la nature) និងតាំងចិត្តអត់ធន់ ហើយដើម្បីអត់ធន់បានត្រូវបំបាត់តណ្ហា រៀនផ្តាច់ចិត្តនិងកុំរវើរវាយទៅលើអ្វីដែលពុំពិត ហើយដើម្បីសំរេចបំនងទាំងអស់នេះបាន មនុស្សត្រូវមានពុទ្ធិជាគោល ព្រោះអវិជ្ជាពុំអាចឲ្យមនុស្សយល់អ្វីបានឡើយ។

**គ៥- សីលធម៌របស់អេពីគារ** : (Epicure) ទស្សនវិទូក្រិចសតវត្សទី៤ មុនគ.ស. បិតនៅត្រង់ការអប់រំមនុស្ស ឲ្យស្វែងរកការសប្បាយតាមធម្មជាតិ ប៉ុន្តែត្រូវចេះជ្រើសរើសយកការសប្បាយសកម្ម (plaisir en mouvement) ផ្ទុយនឹងការសប្បាយស្ងប់ស្ងាត់ (plaisir en repos)។ អេពីគារបានចែកការសប្បាយជា៣ផ្នែក៖

- ការសប្បាយតាមធម្មជាតិនិងចាំបាច់
- ការសប្បាយតាមធម្មជាតិនិងមិនចាំបាច់
- ការសប្បាយមិនតាមធម្មជាតិនិងមិនចាំបាច់។

អេពីគារបានជ្រើសរើសយកការសប្បាយផ្នែកទី១ប្រសើរជាងគេ។

**គ៦- សីលធម៌របស់ម៉ុងតែង** : (Montaigne) អ្នកនិពន្ធបារាំង ១៥៣៣-១៥៩២ បានពោលថា៖

-តាំងចិត្តជាម្ចាស់ចិត្តរបស់ខ្លួន

-កុំធ្វើអ្វីដែលឥតប្រយោជន៍

-កុំបិតនៅក្រោមអំណាចនៃតណ្ហា

-ត្រូវប្រឆាំងនឹងអ្វីដែលមនុស្សភាគច្រើនពុំចូលចិត្ត

**គ៧- សីលធម៌របស់អូគូស្តកុង** : (Auguste Comte) បិតនៅត្រង់៖

- ការពន្យល់តម្លៃនៃសាសនាមនុស្សជាតិ មានន័យថា សាសនាជាការប្រៀនប្រដៅ សម្រាប់អនុវត្តឱ្យបានប្រសើរក្នុងការរស់នៅ

-សាសនាពុំមែនជាការប្រៀនប្រដៅឲ្យគោរពបុគ្គលណាមួយទេទោះបីជាអាទិទេពក្តីតំណាងអាទិទេពក្តី រឺបុគ្គលណាមួយក្តី ទើបអូគូស្តកុងបង្កើតសាសនាមួយឈ្មោះ « សាសនាមនុស្សជាតិ » (la religion de l´ Humanité)

- សាសនានេះបានយកទៅអនុវត្តប្រកបដោយជោគជ័យនៅប្រទេសប្រេស៊ីល(Brésil) ចំណែកឯរដ្ឋាភិបាលប្រេស៊ីល ក៏បានប្រកាសជាផ្លូវការថា បើប្រទេសទាំងអស់លើពិភពលោកនេះយល់តម្លៃទ្រឹស្តី នៃ « សាសនាមនុស្សជាតិ » របស់លោកអូគូស្តកុង ប្រហែលជាសាកលលោកពុំជួបប្រទះសង្គ្រាមទេ។

**គ៨- សីលធម៌របស់ពុទ្ធសាសនាហីនយាន** : បិតនៅត្រង់៖

- ការកសាងកុសល ដូចជាចេះអាណិតអាសូរអ្នកខ្សត់ខ្សោយជាងខ្លួន តាមរយៈរឿងព្រះវេស្សន្តរ (វេស្សន្តរជាតក ក្នុងគម្ពីរទសជាតក)

- ភាពពុំតបតនឹងបាតុភូតទាំងឡាយដែលកើតមានឡើង ពោលគឺបើគេប្រឆាំងត្រូវថយខ្លួនចេញ មិនត្រូវតបតនឹងអ្នកប្រឆាំងទេ ទោះបីគេថាចាញ់ក៏ដោយ

- ពលីកម្មដើម្បីអ្នកដទៃ ដូចជាសុខចិត្តពិបាកខ្លួនឯង ដើម្បីឱ្យអ្នកដទៃបានសប្បាយ

-ការដោះស្រាយបញ្ហាផ្សេងៗដោយសន្តិវិធី ទើបនៅគ្រប់ជាតិរបស់ព្រះពោធិសត្វ ដូចមានអធិប្បាយក្នុងគម្ពីរជាតក គេតែងសង្កេតឃើញថា ការដោះស្រាយប្រកបដោយសន្តិវិធីផ្ទុយពីយុទ្ធវិធី ដូចជាតាមរយៈរឿង

ព្រះវេស្សន្តរ ពេលត្រូវប្រជារាស្ត្របំបរបង់ ព្រះអង្គយល់ព្រមតាមការបំបរបង់។

**គ៩- សីលធម៌របស់ពុទ្ធសាសនាមហាយាន** : ឋិតនៅត្រង់៖

- ការងារនិយម
- សង្គមនិយមដោយយកសង្គមមនុស្សជាគោលដៅ
- មេត្តា ករុណា មុទិតា ឧបេក្ខា

**គ១០- សីលធម៌របស់ព្រាហ្មណ៍សាសនា** : ចាប់កំណើតតាំងពីសតវត្សទី៩មុនគ.ស. ឋិតនៅត្រង់៖

- ការគោរពព្រះអាទិទេព
- ការគោរពពាក្យសច្ចៈ

**គ១១- សីលធម៌របស់គ្រីស្តសាសនា** :

- ព្រះអាទិទេពជួយមនុស្សទាំងអស់ ឱ្យតែមនុស្សប្រាប់ការពិតដល់ព្រះគ្រីស្ត

**គ១២- សីលធម៌របស់អ៊ីស្លាមសាសនា** : មានចែងក្នុងគម្ពីរកូរាន ( CORAN )

- ផ្លូវគំនិតប្រសើរជាងផ្លូវកាយ
- ឱ្យបរិភោគចំពោះអ្នកណាដែលឃ្លាន ( donner à manger à celui qui a faim )
- ហាមមិនឱ្យសម្លាប់មនុស្សម្នាក់ជាដាច់ខាត ព្រោះថាសម្លាប់មនុស្សម្នាក់ដូចជាសម្លាប់មនុស្សទាំងអស់គ្នា
- ស្រលាញ់សន្តិភាព
- យកអំពើល្អឆ្លើយតបនឹងអំពើអាក្រក់
- ប៉ុន្តែលក្ខណៈដែលខ្វះខាត ត្រង់សាសនាអ៊ីស្លាមបង្ខំគេឱ្យជឿព្រះអាទិទេពរបស់ខ្លួនមួយឈ្មោះអាឡ្លាហ៍( Allah )ហើយចាត់ទុកព្រះអាឡ្លាហ៍ជាព្រះអាទិទេពកំពូល :
    - Allah est Dieu unique : អាឡ្លាហ៍ជាអាទិទេពតែមួយអង្គគត់
    - Allah n ´ a pas d ´ égal : អាឡ្លាហ៍គ្មាននរណាស្មើ
    - Allah est créateur de toute chose : អាឡ្លាហ៍ជាអ្នកបង្កើតអ្វីៗសព្វបែបយ៉ាង
    - Allah est invincible : អាឡ្លាហ៍គ្មាននរណាផ្ចាញ់បាន។

**ឃ- សន្និដ្ឋាន**

ជារួមយើងសង្កេតឃើញថាសីលធម៌និមួយៗសុទ្ធសឹងមានតម្លៃរបស់ខ្លួនហេតុនេះយើងពុំអាចអះអាងថា សីលធម៌ណាល្អឬសីលធម៌ណាអាក្រក់បានឡើយ អាស្រ័យលើការអនុវត្តក្នុងជីវភាពរស់នៅ បើការរស់នៅបានប្រសើរ មានន័យថា សីលធម៌នោះប្រសើរ បើការរស់នៅពុំបានប្រសើរទេ គេត្រូវផ្លាស់ប្តូរសីលធម៌នោះ។

តាមន័យទូទៅ គេពុំសូវជួបប្រទះសីលធម៌អាក្រក់ទេ ព្រោះសីលធម៌តែងផ្តល់នូវការអប់រំល្អៗ ទោះបីសីលធម៌ផ្ទាល់ខ្លួនក្តី សីលធម៌ក្នុងគ្រួសារក្តី សីលធម៌ក្នុងវិជ្ជាជីវៈក្តី សីលធម៌ក្នុងសង្គមក្តី និងសីលធម៌ក្នុងពិភពលោក។ប្រទេសណាសំបូរដោយសីលធម៌ល្អគឺជាប្រទេសដែលមានការអប់រំប្រជាពលរដ្ឋដ៏ប្រពៃពីព្រោះការចេះដឹងឯកឯងពុំគ្រប់គ្រាន់ទេ គឺត្រូវទទួលការអប់រំផងទៀតទើបគេចាត់ទុកថាជាប្រទេសមានអរិយធម៌ខ្ពង់ខ្ពស់៕

## ១- សេចក្តីព្រាងច្បាប់ គ្រប់គ្រងទឹកស្អាត

សេចក្តីព្រាងច្បាប់គ្រប់គ្រងទឹកស្អាតត្រូវបានរៀបចំឡើងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការផ្តល់ជំនួយផ្នែកបច្ចេកទេសពីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)។

សេចក្តីព្រាងច្បាប់គ្រប់គ្រងទឹកស្អាតនេះ មានគោលដៅកំណត់ពីក្របខ័ណ្ឌគតិយុត្តសម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍន៍ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងដើម្បីធានា ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ ព្រមទាំងចូលរួមលើកកម្ពស់សុខុមាលភាពសាធារណៈ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋប្រកបដោយបរិយាបន្ន។ ក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ នៃរាជរដ្ឋាភិបាលអាណត្តិទី៦ ការផ្គត់ផ្គង់ទឹកស្អាតគឺជាផ្នែកមួយនៃវិស័យអាទិភាពទាំងបួន មនុស្ស ផ្លូវ ភ្លើង និង ទឹក។

សេចក្តីព្រាងច្បាប់នេះ ត្រូវបានបញ្ជូនមកទីស្តីការគណរដ្ឋមន្ត្រីនៅថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០២១ និងបានឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសនៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួន១៦លើក ចាប់ផ្តើមនៅថ្ងៃទី២៤មិថុនា និងបញ្ចប់នៅថ្ងៃទី២៣ កក្កដា ឆ្នាំ២០២១ តាមរយៈការប្រជុំពីចំងាយ (Zoom Meeting) និងបានឆ្លងប្រជុំអន្តរក្រសួងនៅថ្ងៃទី២ និងទី៣ ខែកញ្ញា ឆ្នាំ២០២១ ដែលដឹកនាំដោយសហប្រធាន ឯកឧត្តមទេសរដ្ឋមន្ត្រី គតិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងឯកឧត្តម **ខូយ ឃុនហ៊ួរ** រដ្ឋលេខាធិការទីស្តីគណរដ្ឋមន្ត្រី។

**ខ្លឹមសារសំខាន់ៗ**

ចំណុចសំខាន់នៃគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតរបស់ក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺ ក្នុងឆ្នាំ ២០៣០ ប្រជាជនកម្ពុជាទូទាំងប្រទេសត្រូវទទួលបានទឹកស្អាតសំរាប់ប្រើប្រាស់គ្រប់ៗគ្នា។ដើម្បីសំរេចទិសដៅនេះក្រសួងត្រូវមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស ដែលបង្កើតឲ្យមានសម្ពាធតម្រូវការថវិកាពីថវិកាជាតិ។ដើម្បីកាត់បន្ថយសម្ពាធតម្រូវការថវិកានេះបទពិសោធន៍របស់ប្រទេសរីកចំរើនជាច្រើនរួមទាំងប្រទេសជប៉ុនដែលបានផ្តល់ជំនួយបច្ចេកទេសសំរាប់ការតាក់តែងច្បាប់ទឹកស្អាតនេះ គឺការអនុញ្ញាតិឲ្យវិស័យឯកជនរួមចំណែកជាដៃគូ ( Private Participation partnership ) ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេស ។ កន្លងមក ការផ្គត់ផ្គង់ទឹកស្អាតក្នុងប្រទេសក៏មានឯកជនរួមចំណែកផ្គត់ផ្គង់ទឹកស្អាតដែរ ប៉ុន្តែ កំរិតនៃការរួមចំណែកនៅមិនទាន់គ្រប់គ្រាន់សំរាប់ផែនការផ្គត់ផ្គង់ទឹកស្អាតទូទាំងប្រទេសក្នុងឆ្នាំ២០៣០ហើយបទដ្ឋានគតិយុទ្ធិសំរាប់វិស័យទឹកស្អាតមិនទាន់មានលក្ខណៈសុក្រិតនៅឡើយ។ច្បាប់ផ្គត់ផ្គង់ទឹកស្អាតថ្មីជាមូលដ្ឋានគតិយុទ្ធិដែលផ្តល់សេចក្តីទុកចិត្តដល់វិនិយោគិនឯកជនដែលមានបំណងរួមចំណែកវិនិយោគទុនសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត។

ធាតុចូលមួយចំនួនដែលក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និង ក្រុមប្រឹក្សាអ្នកច្បាប់ បានស្នើ និងត្រូវបានដំណាងក្រសួងឯកភាពបញ្ចូលក្នុងសេចក្តីព្រាងច្បាប់ ។ ឧទាហរណ៍ ក្នុងមាត្រា ៦ ថ្មី គោលការណ៍ដែលចែងថា ធ្វើឲ្យមានសមភាពនិងមិនមានការរើសអើងរវាងអ្នកផ្តល់សេវា និងអ្នកទទួលសេវាទឹកស្អាត និងក្នុងមាត្រា ៤៦ ដែលចែងពីវិវាទរវាងប្រតិបត្តិករនិងអ្នកប្រើប្រាស់ទឹកស្អាត ដែលចែងថា ភាគីដែលមិនសុខចិត្តអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងទទួលបន្ទុកវិស័យទឹកស្អាតឬមន្ទីរទទួលបន្ទុកវិស័យទឹកស្អាត។

ក្នុងកិច្ចប្រជុំអន្តរៈក្រសួងមានការលើកឡើងពីការកំណត់តម្លៃទឹកស្អាតក្នុងតំបន់ដែលបានទទួលថវិកាសាងសង់ហេដ្ឋារចនាសម្ព័ន្ធជាអំណោយផ្សេងៗ ហើយឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានស្នើសុំឲ្យការកំណត់តម្លៃនេះ ឈរនៅលើគោលការណ៍ស្មើភាពគ្នារវាងអ្នកប្រើប្រាស់សេវាទឹកស្អាតទូទាំងប្រទេស។

*ដោយ កយ បូរី - (ក.ស.វ. - ក្រុម ២)*

## ២- សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

ក្រសួងបរិស្ថានបានធ្វើការកែសម្រួលរចនាសម្ព័ន្ធតួនាទី និងភារកិច្ចអង្គភាពក្រោមឱវាទនីមួយៗរបស់ខ្លួនដើម្បីឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ជាអាទិ៍កំណែ ទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពង្រឹងប្រសិទ្ធភាពការងារឱ្យកាន់តែប្រសើរឡើង សម្រាប់ការគ្រប់គ្រង ការការពារ ការអភិរក្សតំបន់ការពារធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ឆ្លើយតបនឹងបញ្ហាខាងលើនេះ ក្រសួងបរិស្ថានបានរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន ដើម្បីបំពេញនូវកាតព្វកិច្ចជាសេនាធិការឱ្យរាជរដ្ឋាភិបាលកម្ពុជា ក្នុងការរួមចំណែកអនុវត្តនូវគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យបរិស្ថាន ឱ្យកាន់តែមានប្រសិទ្ធភាពថែមទៀត។

សេចក្តីព្រាងអនុក្រឹត្យនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង តាមប្រព័ន្ធអនឡាញ ហ្សូម ដែលបានរៀបចំដោយទីស្តីការគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី១៣ និង ១៤ ខែតុលា ឆ្នាំ២០២១។

ក្នុងដំណើរកិច្ចប្រជុំនេះ តំណាងក្រសួងសាមី បានលើកជូនកិច្ចប្រជុំជ្រាបអំពីសេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថានដើម្បីឱ្យស្របតាមការអនុវត្តនិងតម្រូវការជាក់ស្តែងដែលក្រសួងបរិស្ថានទទួលបន្ទុកការងារដ៏សំខាន់នេះ ជាពិសេសក្នុងដំណាក់កាលបម្រែបម្រួលអាកាសធាតុដូចសព្វថ្ងៃ។ អនុក្រឹត្យថ្មីមាន ១៧ជំពូក ចែកជា ៦១មាត្រា ក្នុងនោះមានការរៀបចំកែលម្អឡើងវិញនូវរចនាសម្ព័ន្ធតួនាទីនិងភារកិច្ចរបស់អគ្គលេខាធិការដ្ឋានអគ្គនាយកដ្ឋាននិងនាយកដ្ឋានមួយចំនួនដែលចាំបាច់បន្ទាប់ពីឆ្លងកាត់បទពិសោធអនុវត្ត អនុក្រឹត្យចាប់ពីឆ្នាំ២០១៦ កន្លងមក។

កិច្ចប្រជុំអន្តរក្រសួងនេះ ត្រូវបានដឹកនាំដោយឯកឧត្តម **កែន សុត្ថា** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពីឯកឧត្តម **នៅ បោន័រ** និង ឯកឧត្តម **ឆាយ ខុម** សមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងក្រុមប្រឹក្សាអ្នកច្បាប់ តំណាងក្រសួងសាមីមាន ឯកឧត្តម ឯកឧត្តម **សៅ សុភាព** រដ្ឋលេខាធិការក្រសួងបរិស្ថាន តំណាងក្រសួង ស្ថាប័ននានា និងមន្ត្រីជំនាញជាអ្នកការពារសេចក្តីព្រាង ព្រមទាំងមន្ត្រីជំនាញអង្គភាពពាក់ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី៕

*ដោយ ឆាយ ខុម - (ក.ស.វ. - ក្រុម ៣)*

# ទីលានប្រជែងភូមិសាស្ត្រនយោបាយ

សង្គ្រាមត្រជាក់គឺជាការតស៊ូភូមិសាស្ត្រនយោបាយ មនោគមវិជ្ជា និងសេដ្ឋកិច្ចរវាងមហាអំណាចពិភពលោកពីរគឺសហរដ្ឋអាមេរិកនិងសហភាពសូវៀតដែលបានចាប់ផ្តើមនៅឆ្នាំ1947នៅចុងបញ្ចប់នៃសង្គ្រាមលោកលើកទីពីរ និងមានរយៈពេលរហូតដល់ការរំលាយសហភាពសូវៀតនៅខែធ្នូ ឆ្នាំ 1991។

ជម្លោះនៅវៀតណាម បានចាក់ឫសក្នុងអំឡុងពេលចលនាទាមទារឯករាជ្យប្រឆាំងនឹងការគ្រប់គ្រងអាណានិគមរបស់បារាំងហើយបានវិវត្តទៅជាការប្រឈមមុខដាក់គ្នាក្នុងសង្គ្រាមត្រជាក់។សង្គ្រាមវៀតណាម (1955-1975) ត្រូវបានប្រយុទ្ធគ្នារវាងវៀតណាមខាងជើងកុម្មុយនិស្ត គាំទ្រដោយសហភាពសូវៀត និងចិន និងវៀតណាមខាងត្បូងគាំទ្រដោយសហរដ្ឋអាមេរិក។

ជាទូទៅអ្នកប្រវត្តិសាស្ត្របានកំណត់មូលហេតុផ្សេងៗគ្នាជាច្រើននៃសង្គ្រាមវៀតណាមរួមមានការរីករាលដាលនៃលទ្ធិកុម្មុយនិស្តកំឡុងសង្គ្រាមត្រជាក់ ការទប់ស្កាត់របស់អាមេរិក និងចក្រពត្តិនិយមអឺរ៉ុបនៅវៀតណាម។ ចំណុចស្នូលនៃជម្លោះគឺការចង់បានរបស់វៀតណាមខាងជើង ដែលបានកម្ចាត់ការគ្រប់គ្រងអាណានិគមបារាំងរបស់វៀតណាមក្នុងឆ្នាំ1954ដើម្បីបង្រួបបង្រួមប្រទេសទាំងមូលនៅក្រោមរបបកុម្មុយនិស្តតែមួយដែលយកគំរូតាមសហភាពសូវៀត និងចិន។

ប្រទេសចិនបានក្លាយទៅជាកុម្មុយនិស្តនៅឆ្នាំ 1949 ហើយកុម្មុយនិស្តបានគ្រប់គ្រងវៀតណាមខាងជើង។សហរដ្ឋអាមេរិកភ័យខ្លាចថាលទ្ធិកុម្មុយនិស្តនឹងរីករាលដាលដល់ប្រទេសវៀតណាមខាងត្បូងនិងតំបន់អាស៊ីផ្សេងទៀត។ អាមេរិកបានសម្រេចចិត្តបញ្ជូនលុយ ការផ្គត់ផ្គង់ និងទីប្រឹក្សាយោធា ដើម្បីជួយរដ្ឋាភិបាលវៀតណាមខាងត្បូង។

ងាកមកមើលភូមិសាស្ត្រនយោបាយបច្ចុប្បន្នដែលរដ្ឋាលប្រធានាធិបតី Joe Biden បាននិងកំពុងរៀបចំឆាកប្រជែងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដោយមានក្តីសង្ឃឹមខ្ពស់ក្នុងការទាក់ទាញមិត្តចាស់នាសម័យកាលសង្គ្រាមនៅវៀតណាមឱយមកគាំទ្រនយោបាយរបស់ខ្លួន—ប្រាំថ្ងៃបន្ទាប់ពីប្រទេសចិននិងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) ដែលមានសមាជិកចំនួន 10 ប្រទេស បានប្រកាសពីការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរបស់ពួកគេទៅជាភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសហរដ្ឋអាមេរិកបានបញ្ជូនអ្នកការទូតជាន់ខ្ពស់របស់ខ្លួនទៅទស្សនកិច្ចចំនួន 4 ប្រទេសនៅក្នុងតំបន់។

លោក Daniel Kritenbrink ជំនួយការរដ្ឋមន្ត្រីការបរទេសអាមេរិក ទទួលបន្ទុកតំបន់អាស៊ីប៉ូស៉ីហ្វិកបានធ្វើដំណើរទៅកាន់ប្រទេសឥណ្ឌូនេស៊ីម៉ាឡេស៊ីសិង្ហបុរីនិងប្រទេសថៃដែលជាផ្នែកមួយនៃការវាយលុកផ្នែកការទូតដោយរដ្ឋបាលប្រធានាធិបតី Joe Biden ដើម្បីបង្កើនការភ្ជាប់ទំនាក់ទំនងជាមួយប្រទេសទាំងនោះ។

អ្នកវិភាគជឿថា អាស៊ីអាគ្នេយ៍បានក្លាយជាទីលានបើកចំហសម្រាប់ការប្រកួតប្រជែងនៅក្នុងល្បែងភូមិសាស្ត្រនយោបាយរវាងប្រទេសដែលមានសេដ្ឋកិច្ចធំជាងគេបំផុតរបស់ពិភពលោក ចាប់តាំងពីសហរដ្ឋ-

អាមេរិកចង់ឱ្យតំបន់នេះចូលរួមជាមួយក្លឹបរបស់ខ្លួន ដើម្បីទប់ស្កាត់និងប្រឆាំងនឹងកំណើនអនុត្តរភាពរបស់ប្រទេសចិន ខណៈដែលទីក្រុងប៉េកាំងបានធ្វើការពិភាក្សាជាមួយប្រទេសក្នុងតំបន់ចេញពីភាពជាដៃគូជាមួយទីក្រុងវ៉ាស៊ីនតោន។

តើអាស៊ីអាគ្នេយ៍ បានឆ្លើយតបយ៉ាងណាហើយ? តើប្រទេសសមាជិកនឹងធ្វើយ៉ាងណា ចំពោះទំនាក់ទំនងចិន-អាមេរិក?

នៅក្នុងការប៉ុនប៉ងបិទបាំងដ៏ស្ដើងដើម្បីប្រឆាំងនឹងប្រទេសចិន រដ្ឋបាលលោក Biden បានចាប់ផ្ដើមជំរុញកិច្ចខិតខំប្រឹងប្រែងដើម្បីលក់គោលគំនិតនៃតំបន់ឥណ្ឌូប៉ាស៊ីហ្វិក"សេរីនិងបើកចំហ"ដែលជាយុទ្ធសាស្ត្រដែលគាត់បានអនុវត្តពីអ្នកកាន់តំណែងមុន នោះគឺលោក Donald Trump ។

ដោយមើលឃើញតំបន់អាស៊ីអាគ្នេយ៍ជាសមរភូមិដ៏សំខាន់ សហរដ្ឋអាមេរិកបានរៀបចំកម្មវិធីដ៏ល្បីមួយដោយបញ្ជូនរដ្ឋមន្ត្រីការពារជាតិរបស់ខ្លួននៅក្នុងខែកក្កដា និងអនុប្រធានាធិបតីនៅក្នុងខែសីហាទៅកាន់តំបន់។ នៅពេលទៅដល់ប្រទេសសិង្ហបុរី អនុប្រធានាធិបតីអាមេរិក Kamala Harris បានប្រកាសថាប្រទេសរបស់គាត់នឹងឈរជាមួយសម្ព័ន្ធមិត្តនិងដៃគូរបស់ខ្លួន"ប្រឈមមុខនឹងការគំរាមកំហែងរបស់ប្រទេសចិន"ហើយបានរិះគន់ចំពោះអ្វីដែលលោកស្រីហៅថា "ការបង្ខិតបង្ខំ និងការគំរាមកំហែង" របស់ទីក្រុងប៉េកាំងលើបញ្ហាសមុទ្រចិនខាងត្បូង។

ទោះបីជាយ៉ាងណាក៏ដោយ ដោយសារវាស្របពេលជាមួយនឹងភាពចលាចលក្នុងប្រទេសអាហ្វហ្គានីស្ថាន ដែលបណ្ដាលមកពីការដកខ្លួនយ៉ាងរហ័ស និងគ្មានការទទួលខុសត្រូវរបស់អាមេរិក បន្ទាប់ពីសង្គ្រាមរយៈពេល 20 ឆ្នាំ និងការដណ្ដើមកាន់កាប់ទីក្រុងកាប៊ុលរបស់ពួកតាលីបង់ ដំណើរទស្សនកិច្ចនេះត្រូវបានគ្របដណ្ដប់ដោយការសាកសួររបស់ប្រទេសក្នុងតំបន់អំពីភាពជឿជាក់នៃការប្ដេជ្ញាចិត្តរបស់សហរដ្ឋអាមេរិក។

កាលពីពាក់កណ្ដាលខែធ្នូឆ្នាំ 2021 រដ្ឋមន្ត្រីការបរទេសអាមេរិកលោក Antony Blinken បានធ្វើការប្ដេជ្ញាចិត្ត"គួរឱ្យកត់សម្គាល់"ទៅកាន់ប្រទេសឥណ្ឌូនេស៊ី ខណៈដែលអ្នកការទូតកំពូលរបស់អាមេរិកបានចាប់ផ្ដើមដំណើរទេសចរណ៍អាស៊ីអាគ្នេយ៍ចំពេលមានភាពតានតឹងកើនឡើងជាមួយប្រទេសចិននៅក្នុងតំបន់។

នៅពេលនោះលោក Blinken បានជួបជាមួយប្រធានាធិបតីឥណ្ឌូនេស៊ី Joko Widodo ហើយបានសង្កត់ធ្ងន់លើសារៈ សំខាន់នៃ "ភាពជាដៃគូយុទ្ធសាស្ត្រ" រវាងប្រទេសទាំងពីរ។ លោក Blinken បានសរសើរ "ការដឹកនាំរបស់ឥណ្ឌូនេស៊ី" នៅក្នុងឥណ្ឌូប៉ាស៊ីហ្វិក ដោយហៅប្រទេសនេះថា "លទ្ធិប្រជាធិបតេយ្យធំជាងគេទី 3 របស់ពិភពលោក និងជាអ្នកគាំទ្រដ៏រឹងមាំនៃបទបញ្ជាអន្តរជាតិផ្អែកលើច្បាប់" ។

រដ្ឋមន្ត្រីការបរទេសលោក Antony Blinken ក៏ត្រូវបានទៅបំពេញទស្សនកិច្ចនៅប្រទេសម៉ាឡេស៊ី និងបានអំពាវនាវឱ្យលោក Dato' Sri Ismail Sabri bin Yaakob នាយករដ្ឋមន្ត្រីនៃម៉ាឡេស៊ី ក្នុងដំណើរទស្សនកិច្ចរបស់រដ្ឋមន្ត្រីBlinkenដែលបានផ្ដល់ឱកាសដ៏ល្អសម្រាប់ម៉ាឡេស៊ីនិងសហរដ្ឋអាមេរិកក្នុងការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការពហុភាគី និងស្វែងរកគំនិតផ្ដួចផ្ដើមរួមគ្នាថ្មីៗ។

កិច្ចសហប្រតិបត្តិការយ៉ាងសកម្មដែលកំពុងបន្តក្នុងវិស័យដូចជាពាណិជ្ជកម្មនិងការវិនិយោគសេដ្ឋកិច្ចឌីជីថលនិងបៃតង សន្តិសុខអ៊ីនធឺណិត ការពារជាតិ សុខភាព ទេសចរណ៍ ការអប់រំ និងទំនាក់ទំនងរវាងប្រជា-

ជន និងប្រជាជនបាននាំមកនូវផលប្រយោជន៍យ៉ាងច្រើនដល់ភាគីទាំងពីរ។

សហរដ្ឋអាមេរិក គឺជាដៃគូពាណិជ្ជកម្ម និងការវិនិយោគដ៏សំខាន់មួយរបស់ម៉ាឡេស៊ី។ ក្នុងឆ្នាំ 2020 ពាណិជ្ជកម្មម៉ាឡេស៊ី-អាមេរិកមានតម្លៃ178.18ពាន់លានRMខណៈពេលដែលចំនួនសរុបនៃការវិនិយោគដែលត្រូវបានអនុម័តពីសហរដ្ឋអាមេរិកក្នុងវិស័យផលិតកម្មនៅក្នុងប្រទេសម៉ាឡេស៊ីមានតម្លៃ 3.7 ពាន់លាន RM ។

ភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងសហរដ្ឋអាមេរិក និងម៉ាឡេស៊ី នៅតែបន្តជាក្របខណ្ឌដ៏ទូលំទូលាយសម្រាប់កិច្ចសហប្រតិបត្តិការសកម្ម ពហុភាគី និងផ្តល់ផលប្រយោជន៍ ទៅវិញទៅមករវាងប្រទេសទាំងពីរ។

ខណៈភាពតានតឹងកើនឡើងរវាងសហរដ្ឋអាមេរិកនិងចិនបញ្ហាអន្តរជាតិនិងតំបន់ដែលជាក្តីកង្វល់រួមក៏ត្រូវបានលើកឡើងផងដែរក្នុងអំឡុងពេលដំណើរទស្សនកិច្ចផ្លូវការរបស់រដ្ឋមន្ត្រី Blinken។

ម្យ៉ាងវិញទៀត រដ្ឋមន្ត្រីការបរទេសអាមេរិក បានសម្តែងការសោកស្តាយចំពោះការលុបចោលដំណើរទស្សនកិច្ចទៅកាន់ប្រទេសថៃ។ ដូចដែលបានរាយការណ៍នៅក្នុងព័ត៌មាន សមាជិកនៃសារព័ត៌មានដែលធ្វើដំណើរជាមួយគណៈប្រតិភូរបស់លោក Antony Blinken រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកបានធ្វើតេស្តវិជ្ជមាន COVID-19។

មិនយូរប៉ុន្មាន រដ្ឋមន្ត្រីការបរទេសអាមេរិកលោក Antony Blinken បានទូរស័ព្ទទៅឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសថៃ លោក Don Pramudwinai ដើម្បីសម្តែងការសោកស្តាយយ៉ាងខ្លាំង ដែលមិនអាចធ្វើដំណើរទៅប្រទេសថៃនៅពេលនេះដោយសារតែចង់កាត់បន្ថយហានិភ័យនៃការរីករាលដាលនៃCOVID-19 ដោយដាក់សារៈសំខាន់លើសុខភាព និងសុវត្ថិភាពរបស់សមាជិកគណៈ ប្រតិភូអាមេរិក និងអ្នក ដែលគណៈប្រតិភូអាមេរិកគ្រោងនឹងធ្វើទំនាក់ទំនងជាមួយ។

ជាការគួរសមការទូតរដ្ឋមន្ត្រីការបរទេសអាមេរិកបានអញ្ជើញឧបនាយករដ្ឋមន្ត្រីនិងជារដ្ឋមន្ត្រីក្រសួងការបរទេសថៃមកបំពេញទស្សនកិច្ចនៅសហរដ្ឋអាមេរិកក្នុងពេលឆាប់ៗ ហើយសង្ឃឹមថានឹងមានឱកាសទៅបំពេញទស្សនកិច្ចនៅប្រទេសថៃនាពេលខាងមុខ ដោយបានគូសបញ្ជាក់ថា លោកនឹងប្រើប្រាស់ទំនាក់ទំនងនាពេលខាងមុខ ដើម្បីពង្រឹងទំនាក់ទំនងថៃ-អាមេរិកឱ្យកាន់តែស៊ីជម្រៅថែមទៀត។

ប្រភព៖ SCMP, Sideshow by William Shawcross, Al Jazeera

*ដោយ នរ៉ាណាឫទ្ធិ អានន្ទជាយ៉ាត*

# បញ្ហាដែនដីកូសាំងស៊ីន និងបញ្ហាព្រំដែន

នៅក្នុងគ.ស.១៨៦៤ ព្រះបាទ នរោត្តម ដោយមានលោក ឌូដា ដឺ ឡាគ្រេ( Doudart de Lagrée ) អមផង បានយាងទៅជួបលោកទេសាភិបាល ដឺឡា គ្រង់ឌីយែរ ( de la Grandière ) នៅក្នុងទីក្រុងព្រៃនគរ ហើយបានធ្វើសំណូមពរចំពោះលោកទេសាភិបាល សូមឱ្យប្រទេសបារាំងបង្វិលសងមកខ្មែរវិញនូវខេត្តទាំងអស់គឺ លង់ហោរ (លង់ហោរ ព្រះត្រពាំង ផ្សារដែក) មាត់ជ្រូក (មាត់ជ្រូក បារាជ ព្រៃកប្បស្សី ឃ្លាំង) និងពាម(ពាម ក្រមួនស ពលលាវ)ដែលស្ថិតនៅក្នុងការកាន់កាប់របស់យួននៅឡើយ តាមសន្ធិសញ្ញា១៨៦២។ ព្រះអង្គទ្រង់បានទទួលពាក្យសន្យាពីរឿងនេះ ហើយក៏យាងត្រឡប់ចូលរាជធានី ឧដុង្គវិញ ដោយទ្រង់មានសង្ឃឹមថាទឹកដីដែលបាត់បង់ទៅនោះ នឹងត្រូវបានបញ្ចូលជាទឹកដីខ្មែរដូចដើមវិញមិនខាន។ ក៏ប៉ុន្តែនៅគ.ស.១៨៦៧ ដោយហេតុថាខេត្តទាំងបីនោះជាកន្លែងដែលយួនធ្វើសកម្មភាពប្រឆាំងបារាំង លោកទេសាភិបាលកូសាំងស៊ីនក៏វាយយកបញ្ចូលជាអាណានិគមរបស់លោកតរៀងទៅ ដោយភ្លេចនឹកដល់ពាក្យសន្យារបស់លោកចំពោះព្រះបាទនរោត្តម។

ដូចនេះ ចាប់តាំងពីគ.ស.១៨៦៧ ទឹកដីកម្ពុជាក្រោមទាំងមូលបានក្លាយទៅជាអាណានិគមរបស់បារាំង។ ចំណែកឯកម្ពុជាលើមានលក្ខន្តិកៈជាប្រទេសអាណាព្យាបាល។ ម្ល៉ោះហើយ អាជ្ញាធរបារាំងនៅកូសាំងស៊ីនតែងតែធ្វើការកែប្រែបន្ទាត់ព្រំដែនតាមទំនើងចិត្តខ្លួន រវាងប្រទេសទាំងពីរ ដែលមានរបបខុសគ្នាដោយសម្អាងលើហេតុផលខាងរដ្ឋបាល ឬខាងសេដ្ឋកិច្ច។ គេបានសង្កេតឃើញថា ការកែប្រែទាំងនោះសុទ្ធតែធ្វើឱ្យចំណេញទឹកដីទៅខាងកូសាំងស៊ីនជានិច្ច ដោយមិនអើពើដល់ការតវ៉ារបស់ព្រះរាជាខ្មែរ ឬដោយមិនស្នើសួរព្រះយោបល់ផងទេ។ ចាប់ពីឆ្នាំ១៨៩៣ដល់ឆ្នាំ១៩១៤ប្រទេសខ្មែរត្រូវបាត់បង់ទឹកដីថែមមួយភាគទៀតដោយហេតុតែបារាំង បានប្រវញ្ចយកទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីន ឬក្នុងប្រទេសអណ្ណាមទៅវិញ។

នៅគ.ស.១៨៩៨ លោករ៉េស៊ីដង់ស៊ុប៉េរីយ៉រ នៃប្រទេសលាវបានដកហូតយកពីខេត្តស្ទឹងត្រែង នូវដីមួយដុំ ដើម្បីបង្កើតជាស្នងការដ្ឋាន ដាឡាក (Darlac) ដែលក្រោយមកត្រូវគេយកទៅបញ្ចូល ក្នុងប្រទេសអណ្ណាម នៅគ.ស.១៩២៩។ នៅគ.ស. ១៨៩៣ អនុក្រឹត្យ( arrêté ) របស់លោកទេសាភិបាល កូសាំងស៊ីនបានបញ្ចូលស្រុកខ្មែរពីរគឺ គីវអាញ់( Cuu Anh ) និង ថាញ់អាញ់ (Than Anh ) នៅឯនាយ ឡុកនិញ ( Loc Ninh ) និងស្រុកស្មៀងពីរគឺ ឡុកនិញ និង ភឿកឡេ ( Phuoc Lê ) ទៅក្នុងស្រុក ( huyên ) កាន់ឡេ( Can Lê ) ក្នុងបំណងដើម្បីកែនមនុស្សទៅស្ថាបនាផ្លូវពី បៀនវ៉ា ទៅ ក្រចេះ។ ផែនទីដែលបោះពុម្ពមុនឆ្នាំ១៩០៣ សុទ្ធតែដាក់ថា ស្រុក ឡុកនិញ និង ភឿកឡេ ជាទឹកដីខ្មែរទាំងអស់។

លុះមកដល់ឆ្នាំ១៩១៤ ទើបមានអនុក្រិត្យមួយរបស់លោកអគ្គទេសា ភិបាលសម្រេចបញ្ចូលស្រុកពីរនោះទៅក្នុងដែនដីកូសាំងស៊ីន។

ខាងផ្នែកពេងដំរីលិខិតផ្លូវការជាច្រើនបានបញ្ជាក់ពីការដកហូតយកដីខ្មែរទៅបញ្ចូលក្នុងដែនកូសាំងស៊ីន គឺស្រុក ជើងបាដែង បឹងជ្រុំ ស្រុកត្រាញ់ និងដីស្ថិតនៅត្រង់ចន្លោះនៃទន្លេ វាយគោ ( Vaico ) ទាំងពីរ។

ខាងផ្នែកពាម បារាំងបានយកឃុំពីរគឺ កោះចន្លុះ និង សាគី នៅគ.ស. ១៨៩៣ ដើម្បីយកទៅបញ្ចូលក្នុងដែនកូសាំងស៊ីនទៀត។ មានអនុក្រិត្យមួយរបស់លោកអគ្គទេសាភិបាលធ្វើនៅឆ្នាំ១៩១៤ បានបញ្ជាក់ពីរឿងនេះ។

ចំពោះកោះទាំងឡាយវិញ អាជ្ញាធរបារាំងនៅកូសាំងស៊ីន ក៏ដូចជាអាជ្ញាធរបារាំងនៅប្រទេសកម្ពុជាសុទ្ធតែបានទាមទារទុកជាកម្មសិទ្ធិតែរៀងៗខ្លួន។ តាមផ្លូវច្បាប់ គេឃើញមានសារាចរមួយរបស់លោកអគ្គ-ទេសាភិបាល ប្រេវីយេ (Brévié) ចុះថ្ងៃទី៣១ ខែមករា ១៩៣៩ ដែលបានចែងថា «កោះទាំងឡាយដែលស្ថិតនៅខាងជើងបន្ទាត់មួយកែងនឹងឆ្នេរសមុទ្រត្រង់ចំណុចព្រំដែនរវាងប្រទេសកម្ពុជានិងកូសាំងស៊ីននឹងត្រូវ

គ្រប់គ្រងដោយប្រទេសកម្ពុជា។ អាជ្ញាធរ អាណាព្យាបាល នឹងរ៉ាប់រងជាពិសេសនូវបញ្ហាប៉ូលីសលើកោះទាំងនោះ។

ចំណែកឯកោះទាំងឡាយដែលស្ថិតនៅខាងត្បូងបន្ទាត់នោះ គិតទាំងកោះត្រល់ទាំងមូលផងនឹងត្រូវគ្រប់គ្រងដោយអាជ្ញាធរដែនកូសាំងស៊ីន។

ដូចនេះយើងឃើញថាព្រំដែនរវាងប្រទេសកម្ពុជានិងដែនដីកូសាំងស៊ីនមានលក្ខណៈជាព្រំដែនរដ្ឋបាលច្រើនជាងព្រំដែននយោបាយ។ ខ្មែរត្រូវបាត់បង់ទឹកដីទទេៗព្រមទាំងកោះខ្លះ រួមមាន កោះត្រល់ជាដើម មកតែពីចិត្តលោភលន់របស់បារាំងតែប៉ុណ្ណោះ។

ចាប់តាំងពីគ.ស.១៨៨៧តទៅ ប្រទេសខ្មែរបានស្ថិតនៅក្នុងសន្តិភាពប៉ុន្តែទឹកដីត្រូវបារាំងខ្វេះយកម្តងម្តុំៗ យកទៅបញ្ចូលឯណេះ ឬឯណោះតាមតែអំពើចិត្តរបស់ខ្លួន។

ដែនដីកូសាំងស៊ីនត្រូវបានបារាំងភ្ជាប់ទៅនឹងវៀតណាម នៅថ្ងៃទី ០៨ ខែមីនា ឆ្នាំ១៩៤៩។ ដូចនេះកូសាំងស៊ីន អស់មានលក្ខន្តិកៈជាដែនដី(បារាំង)ឯនាយសមុទ្រទៀតហើយ។ ប្រធានាធិបតីបារាំង វ៉ាំងសង់អូរីយ៉ូល ចុះហត្ថលេខាសម្រេចចុងក្រោយនៅ ទូឡុង ថ្ងៃទី០៤ មិថុនា ១៩៤៩។ ទឹកដីកម្ពុជាក្រោមមានទំហំ ៦៨,៩៦៥គ.ម២ ចែកចេញជា ២១ខេត្ត ១៧១ស្រុក ១៣៦៨ឃុំ និង ១៤៧៧៨ភូមិ។ មានប្រជាជនរស់នៅជាង១៣លាននាក់ដែលលាយចម្រុះទៅដោយជនជាតិយួនខ្មែរចាមក្នុងនោះមានជនជាតិខ្មែរប្រមាណ៧លាននាក់។ ឈ្មោះខេត្តទាំងម្ភៃមួយរបស់កម្ពុជាក្រោមគឺ៖

| | | |
|---|---|---|
| ១. ខេត្តព្រះត្រពាំង | យួនហៅប្រែជា | ត្រាវិញ |
| ២. ខេត្តឃ្លាំង | យួនហៅប្រែជា | សុកចាង |
| ៣. ខេត្តមាត់ជ្រូក | យួនហៅប្រែជា | ចូវដុក |
| ៤. ខេត្តពាមបារាជ | យួនហៅប្រែជា | ឡុងស្វៀន |
| ៥. ខេត្តពលលាវ | យួនហៅប្រែជា | បាច់លីវ |
| ៦. ខេត្តក្រមួនស | យួនហៅប្រែជា | រ៉ាចយ៉ា |
| ៧. ខេត្តពាមបន្ទាយមាស | យួនហៅប្រែជា | ហាទៀង |
| ៨. ខេត្តទឹកខ្មៅ | យួនហៅប្រែជា | កាម៉ៅ |
| ៩. ខេត្តព្រែកឫស្សី | យួនហៅប្រែជា | កាន់ថឺ |
| ១០. ខេត្តលង់ហោ | យួនហៅប្រែជា | វិញឡុង |
| ១១. ខេត្តរោងដំរី | យួនហៅប្រែជា | តាយនិញ |
| ១២. ខេត្តព្រៃនគរ | យួនហៅប្រែជា | សាយហ្គន(HCM) |
| ១៣. ខេត្តទួលតាមោក | យួនហៅប្រែជា | ធូដាយម៉ុត |
| ១៤. ខេត្តផ្សារដែក | យួនហៅប្រែជា | សាដែក |
| ១៥. ខេត្តចង្វារត្រពាំងស្រកាត្រី | យួនហៅប្រែជា | បៀនហោ |
| ១៦. ខេត្តមេ ស | យួនហៅប្រែជា | មីថឺ |
| ១៧. ខេត្តព្រះសួគ៌ា | យួនហៅប្រែជា | បារា |
| ១៨. ខេត្តអូរកាប់ | យួនហៅប្រែជា | វង់តាវ |
| ១៩. ខេត្តកំពង់ឫស្សី | យួនហៅប្រែជា | បេនត្រែ |
| ២០. ខេត្តកំពង់គោ | យួនហៅប្រែជា | តាំងអាន |
| ២១. ខេត្តកោះកោង | យួនហៅប្រែជា | កូកុង |

*រៀបរៀងដោយ - បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង*

## ១- បច្ចេកសព្ទភូមិវិទ្យាប្រជាជន

១-ការវិភាគប្រជាសាស្ត្រ វិធីមួយសម្រាប់វាយតម្លៃភាពត្រឹមត្រូវនៃជំរឿនណាមួយដោយប៉ាន់ស្មានសមាសភាគប្រជាសាស្ត្រ ដោយគិតពីជំរឿនមុននិងប្រៀបធៀបជាមួយនឹងជំរឿនថ្មី។ eng. demographic analysis

២-កំណើនធម្មជាតិ ចំនួនប្រជាជនដែលអ្នកកើតលើសចំនួនអ្នកស្លាប់។ eng. natural increase

៣-កំណើនប្រជាជន ការកើនចំនួនប្រជាជនសរុប ដែលជាលទ្ធផលរវាងការកើត ការស្លាប់ និងបម្លាស់លំនៅ ក្នុងភូមិសាស្ត្រជាក់លាក់និងក្នុងរយៈពេលកំណត់ណាមួយ។ eng. population increase

៤-គេហព័ន្ធ មនុស្សទាំងអស់ដែលរស់នៅក្នុងឯកតាលំនៅឋានមួយ(ផ្ទះ បន្ទប់ ទូក ផ្ទះទឹក...)។ គេហព័ន្ធមួយអាចមានមនុស្សជាសាច់ញាតិឬមិនមែនជាសាច់ញាតិនឹងគ្នា។ eng. household

៥-គោលនយោបាយប្រជាជន វិធានការរបស់រដ្ឋដើម្បីមានឥទ្ធិពលទៅលើទំហំ កំណើន របាយ ឬសមាសភាពប្រជាជន ក្នុងពេលបច្ចុប្បន្នឬអនាគត។ eng. population policy

៦-គ្រួសារ ក្រុមមនុស្សដែលមានចំណងទាក់ទងនឹងគ្នាដោយសារកំណើត អាពាហ៍ពិពាហ៍ ការទទួលចិញ្ចឹម ហើយរស់នៅជាមួយគ្នា ដូចជាឪពុក ម្ដាយ កូន...។ eng. family

៧-ចំណាកប្រទេស/និរប្រវេសន៍ បម្លាស់លំនៅនៃប្រជាជនដែលចេញពីប្រទេសកំណើតឬប្រទេសណាមួយដែលខ្លួនកំពុងរស់នៅ ដើម្បីទៅរស់នៅឬធ្វើការនៅប្រទេសផ្សេង។ eng. emigration

៨-ចំណាកស្រុក បម្លាស់លំនៅនៃប្រជាជនក្នុងប្រទេស ដែលចេញពីតំបន់មួយទៅកាន់តំបន់ផ្សេង ដើម្បីស្វែងរកការងារឬតាំងទីលំនៅថ្មី។ eng. out-migration

៩-ចំណូលស្រុក បម្លាស់លំនៅនៃប្រជាជនក្នុងស្រុកដែលចូលមករស់នៅកន្លែងណាមួយដោយចេញពីតំបន់ផ្សេង ដើម្បីស្វែងរកការងារឬតាំងទីលំនៅថ្មី។ eng. in-migration

១០-ចំណោលជនបទ បម្លាស់លំនៅនៃប្រជាជនដែលចេញពីជនបទស្រែចម្ការ ទៅកាន់ទីក្រុងឬតំបន់ឧស្សាហកម្ម ដើម្បីស្វែងរកការងារ។ eng. rural exodus

១១-ជីវភាពប្រជាសាស្ត្រ ដំណើរប្រែប្រួលឥតឈប់ឈរនៃទំហំនិងសមាសភាពនៃអាយុនិងភេទរបស់ប្រជាជនមួយ ជាលទ្ធផលនៃដំណើរវិវត្តផ្នែកជីវសាស្ត្រនិងផ្នែកបរិស្ថានដែលជាកត្តា ដូចជាអត្រាកើត ស្លាប់ អន្តោប្រវេសន៍ និងនិរប្រវេសន៍។ ចំនួនប្រជាជនក្មេងឬចាស់ កំណើនប្រជាជនទាបឬខ្ពស់ប្រជាជនកើនចំនួនឬថយចុះអាស្រ័យដោយជីវភាពប្រជាសាស្ត្រ(ពាក្យនេះមានន័យដូចឌីណាមិកប្រជាសាស្ត្រ)។ eng. demographic dynamics

១២-ជាតិប្រមាណ ចំនួនកំណើតរស់ក្នុងចំណោមប្រជាជនសរុប នៅកន្លែងណាមួយ និងក្នុងរយៈពេលកំណត់។ អត្រាជាតិប្រមាណគិតជាភាគពាន់ក្នុង១ឆ្នាំ។ eng. natality

១៣-ជំនាន់កំណើត ក្រុមមនុស្សដែលកើតក្នុងឆ្នាំឬក្នុងព្រឹត្តិការណ៍ណាមួយជាមួយគ្នា។ eng.birthcohort

១៤-ជំរឿនប្រជាជន ការរាប់ចំនួនប្រជាជនប្រុសស្រី ក្មេងចាស់ដែលកំពុងរស់នៅក្នុងប្រទេសមួយ ជាប្រជាពលរដ្ឋរបស់ខ្លួន និងជាជនបរទេសអន្តោប្រវេសន៍ លើកលែងតែជនបរទេសមិនមែនអន្តោប្រវេសន៍ដែលត្រូវបានកំណត់ដោយឡែក។ eng. population census

១៥-ដង់ស៊ីតេប្រជាជន ចំនួនប្រជាជនក្នុងផ្ទៃដីមួយគីឡូម៉ែត្រការ៉េ។ eng. density of population

១៦-ដំណុះប្រជាជន ការកើតមានឬកំណើនប្រជាជនយ៉ាងឆាប់រហ័សនៅតំបន់ណាមួយនៃ ពិភពលោកដោយសារមានចំណូលប្រជាជនមកពីក្រៅធ្វើឱ្យតំបន់មួយដែលពីមុនគ្មានមនុស្សឬមានតិច ទៅជាមានប្រជាជនច្រើន។ ដំណុះនេះអាចនិយាយចំពោះ ប្រទេសមួយក៏បាន។ ឧ.ដំណុះប្រជាជនស្បែកខ្មៅនៅទ្វីបអាមេរិកខាងជើង ស.វ.ទី១៦ និង១៧។ eng. populating

១៧-បម្លាស់លំនៅ ដំណើរផ្លាស់ទីរបស់មនុស្សជាបណ្ដោះអាសន្នឬស្ថាពរពីតំបន់មួយទៅតំបន់មួយផ្សេងទៀត។ បម្លាស់លំនៅមានបម្លាស់លំនៅក្នុងប្រទេសនិងបម្លាស់លំនៅអន្តរជាតិ។ eng. migration

១៨-ប្រជាជន ជនទាំងអស់ដែលកំពុងរស់នៅក្នុងប្រទេសមួយរួមទាំងជនបរទេសអន្តោប្រវេសន៍។ eng. population

១៩-ប្រជាជនក្មេង ប្រជាជននៃតំបន់ឬប្រទេសណាមួយដែលមនុស្សវ័យកុមារវ័យជំទង់និងទើបពេញវ័យមានសមាមាត្រខ្ពស់ក្នុងចំណោមប្រជាជនសរុប។ eng. young population

២០-ប្រជាជនចាស់ ប្រជាជននៃតំបន់ឬប្រទេសណាមួយ ដែលមនុស្សពេញវ័យនិងវ័យចាស់ មានសមាមាត្រខ្ពស់ក្នុងចំណោមប្រជាជនសរុប។ eng. old population

២១-ប្រជាជនលើសបន្ទុក ស្ថានភាពនៃប្រជាជននៅកន្លែងណាមួយ(តំបន់ប្រទេស)ដែលមានចំនួនច្រើនលើសពីលទ្ធភាពសេដ្ឋកិច្ច។ eng. overpopulation

២២-ប្រជាពលរដ្ឋ ជនទាំងឡាយដែលមានសញ្ជាតិរបស់រដ្ឋដែលខ្លួនកំពុងរស់នៅ។ eng. citizen

២៣-ប្រជាសាស្ត្រ ការសិក្សាអំពីប្រជាជនតាមបែបស្ថិតិវិទ្យា។ eng. demography

២៤-ផែនការគ្រួសារ គម្រោងឱ្យមានកូនតាមបំណង ដូចជាការពន្យារកំណើត ការអប់រំ សុខភាព ការទប់កំណើតជាដើម ដើម្បីកាត់បន្ថយការប៉ះពាល់ដល់សុខភាពម្ដាយ និងកូន ព្រមទាំងសេដ្ឋកិច្ចគ្រួសារ។ eng. family planning

២៥-ភាពបង្កកំណើត/លទ្ធភាពមានកូន សម្បទាដែលស្ត្រីម្នាក់អាចផ្ដល់កំណើតកូនបាន ក្នុង មួយជីវិតរបស់គាត់។ eng. fertility

**២៦-ភូមិវិទ្យាប្រជាជន** ផ្នែកមួយនៃភូមិវិទ្យាមនុស្សដែលសិក្សាអំពីការប្រែប្រួលនៃរបាយ ដង់ស៊ីតេ សមាសភាព លំនៅឋាន ក្រុង បម្លាស់លំនៅ និងកំណើនប្រជាជនទៅតាមកន្លែងផ្សេងៗ។ eng. population geography

**២៧-ពីរ៉ាមីត**
**២៨-មរណប្រមាណ** ការបង្ហាញដោយក្រាហ្វដើម្បីតាងទម្រង់តាមអាយុនិងភេទនៃប្រជាជនណាមួយ ក្នុងពេលវេលាជាក់លាក់ ចាប់ពីអាយុ0ឆ្នាំដល់អាយុច្រើនបំផុត។ ពីរ៉ាមីតមានទម្រង់ខុសៗគ្នាដោយកត្តាជាតិប្រមាណ មរណប្រមាណ និងបម្លាស់លំនៅ។eng. pyramid

**២៩-របាយប្រជាជន** ចំនួនស្លាប់ក្នុងចំណោមប្រជាជនសរុប នៅកន្លែងណាមួយនិងក្នុងរយៈពេលកំណត់។ អត្រាមរណប្រមាណគិតជាភាគពាន់ក្នុង១ឆ្នាំ។ eng. mortality

**៣០-របេកក្រុង** ការតាំងទីលំនៅរបស់ប្រជាជនដែលមានលក្ខណៈប្រមូលផ្តុំឬរាយប៉ាយនៅតាមទីតាំងភូមិសាស្ត្រនានា ដោយសារកត្តាផ្សេងៗ។ eng. population distribution
ការរីកក្រុងបណ្តាលមកពីលំហូរប្រជាជនច្រើនពីជនបទឬពីកន្លែងផ្សេងទៀត។ eng. urbanization

---

*ដោយ បណ្ឌិតសភាចារ្យ ឆយ អូន*

# ២- ស្វែងយល់ពីបុណ្យកឋិន ឬ កឋិនទាន

កឋិន ន.:គឺជាពាក្យបាលីប្រែថា សំពត់ដែលទាយកប្រគេនដល់ភិក្ខុសង្ឃក្នុងកឋិនកាល។ ឯបុណ្យកឋិន គឺជាបុណ្យប្រគេនដល់ព្រះសង្ឃ ក្រោយពេលដែលព្រះសង្ឃគង់ចាំវស្សា អស់ត្រីមាសក្នុងទីអាវាសណាមួយ។

បុណ្យកឋិនជាបុណ្យដ៏ធំមួយ ដែលពុទ្ធសាសនិកជននិយមធ្វើមួយឆ្នាំម្តង ក្នុងរយៈពេល១ខែ ពីថ្ងៃ១រោជ ខែអស្សុជដល់ថ្ងៃ១៥កើតខែកត្តិក។

ក- កំណើតនិងបុព្វហេតុនៃបុណ្យកឋិន : បុណ្យកឋិនមានកំណើតតាំងពីសម័យពុទ្ធកាលមកម្លេះ។ បុព្វហេតុនាំឱ្យមានបុណ្យកឋិននេះឡើង ដោយសារនៅសម័យនោះ មានភិក្ខុសង្ឃ៣០អង្គ ធ្វើដំណើរពីដែនបាវេយ្យៈ នាក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះពុទ្ធអង្គ ដែលគង់នៅវត្តជេតពន។ ក្នុងពេលរដូវវស្សា មានភ្លៀងធ្លាក់ជោគជាំបណ្តាលឱ្យស្បង់ចីពរទទឹកទ្រុឌទ្រោមអស់គ្មានសល់ឃើញដូច្នោះទើបព្រះពុទ្ធអង្គទ្រង់អនុញ្ញាតឱ្យឧបាសកឧបាសិកាធ្វើអង្គកឋិនចំពោះព្រះសង្ឃដែលគង់ចាំវស្សាអស់មួយត្រីមាសតាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ។

ខ- អានិសង្សបុណ្យកឋិន : អានិសង្ស គឺផលល្អ ផលបុណ្យ ឬផលនៃកុសល ។ តាមទស្សនៈនៃព្រះពុទ្ធសាសនា ការធ្វើបុណ្យកឋិនបានអានិសង្សច្រើនណាស់ ទាំងព្រះសង្ឃនិងទាំងទាយកអ្នកធ្វើ ។

ខ$_១$- ចំពោះព្រះសង្ឃដែលជាអ្នកទទួលក្រាលកឋិន (តំណាងព្រះសង្ឃគ្រប់អង្គ) ត្រូវបានទទួលអានិសង្សប្រាំគឺ :

- អានាមន្តចារោ គឺធ្វើឱ្យភិក្ខុដែលបានក្រាលអនុមោទនាកឋិនទាន រួចចាកអាបត្តិចារិត្តសិក្ខាបទទី៦។
- សមាទានចារោ គឺអាចធ្វើឱ្យភិក្ខុក្រាលកឋិនទាន បានរួចចាកអាបត្តិក្នុងទុតិយកឋិនសិក្ខាបទទី២។
- គណភោជនំ គឺអាចធ្វើឱ្យភិក្ខុដែលក្រាលកឋិនទាន បានរួចចាកអាបត្តិក្នុងគណៈភោជនសិក្ខាបទទី២។
- យាវទត្ថចីវរំ គឺអាចធ្វើឱ្យភិក្ខុដែលក្រាលកឋិនទាន បានរួចចាកអាបត្តិក្នុងបឋមកឋិនសិក្ខាបទទី១ ក្នុងចិវរវគ្គនៃនិស្សគ្គិយបាចិត្តិយៈបាន។
- យោចតុត្ថចីវរុប្បាទោសោ នេសំភវិស្សតិ គឺអាចធ្វើឱ្យភិក្ខុដែលក្រាលកឋិនទានបាន អនុមោទនាកឋិនមានអំណាចទទួលចំណែកលាភ ដែលកើតឡើងក្នុងទីអាវាសដែលខ្លួនចាំវស្សា ។

ខ$_២$- ចំពោះទាយកអ្នកប្រគេន ដែលមានសន្តានចិត្តល្អ សទ្ធាជ្រះថ្លានឹងបុណ្យកឋិននេះ ក៏ត្រូវទទួលផលានិសង្សច្រើនធំធេង លើសពិធីបុណ្យផ្សេងៗទៀតក្នុងជាតិនេះ និងជាតិខាងមុខ ។ អាស្រ័យដោយផលានិសង្សច្រើនដូចបានរៀបរាប់ខាងលើនេះ ទើបពុទ្ធសាសនិកជនខ្មែរ គ្រប់រូប និយមធ្វើបុណ្យកឋិននេះណាស់ គេតែងសន្សំប្រាក់កាសសម្រាប់ធ្វើបុណ្យនេះឱ្យបានម្តងយ៉ាងតិចក្នុងមួយជីវិតរបស់ខ្លួន ហើយបើបានធ្វើច្រើនដងកាន់តែល្អប្រសើរថែមទៀត ។ ចំពោះអ្នកដែលបាន ចូលរួមចាប់កុសលក្នុងបុណ្យកឋិន ក៏ទទួលផលបុណ្យដូចៗគ្នាដែរ ។

គ- កឋិនទាយក ឬអ្នកប្រគេនកឋិន : អ្នកធ្វើបុណ្យកឋិនហៅថា « កឋិនទាយក » ជាមនុស្សគ្រប់ប្រភេទជាព្រះសង្ឃក្តី គ្រហស្ថក្តី អាចប្រគេនសំពត់កឋិនចំពោះព្រះភិក្ខុសង្ឃបានទាំងអស់។ ទាយកអ្នកប្រគេនកឋិន

ត្រូវមានស្បង់ចីពរ សង្ឃាដីជាការចាំបាច់ខានមិនបាន ។ ចីពរនិងសង្ឃាដីត្រូវថ្មី ចាស់មិនបានប្រើហើយក៏មិនបាន គឺថ្មីសុទ្ធ ឬមួយយកក្រណាត់ទាំងដុលមកកាត់ដេរជ្រលក់ នៅពេលនោះតែម្តង។

ឃ-ក្រាលកឋិនឬគ្រងកឋិន:ក្រាលកឋិនឬគ្រងកឋិនហៅបានដូចគ្នា។ក្រាលកឋិនត្រូវធ្វើក្នុងព្រះវិហារដោយមានព្រះសង្ឃយ៉ាងតិចបំផុតប្រាំអង្គ ។ បើខ្វះពុំគ្រប់ចំនួន ត្រូវនិមន្តព្រះសង្ឃពីវត្តផ្សេងទៀតមកបង្គ្រប់ចំនួន។ប្រសិនបើរកព្រះសង្ឃពុំគ្រប់ចំនួនប្រាំអង្គទេ គេពុំអាចក្រាលកឋិនបានឡើយ ។បណ្តាភិក្ខុទាំងប្រាំអង្គនេះ បួនអង្គជាជំនុំសង្ឃចតុវគ្គ ជាអ្នកប្រគល់កឋិន និងភិក្ខុមួយអង្គទៀតជាអ្នកក្រាលកឋិន ។ ភិក្ខុដែលក្រាលកឋិននេះ ត្រូវជាអ្នកដែលមានវស្សាចាស់ជាងគេ តែបើភិក្ខុអង្គនោះមិនទទួលដោយប្រការណាមួយ ដូចជាភិក្ខុដទៃមានចីពរដាច់ដាចជាង អាចប្រគល់ទៅឱ្យភិក្ខុអង្គនោះ ជាអ្នកគ្រងជំនួសបាន ។

ង-សម្ភារៈបរិក្ខាកឋិន:សម្ភារៈបរិក្ខាកឋិនត្រូវមាន:ចីវរមួយត្រៃ និងប្រដាប់ប្រដាពីរលៀងអមសងខាងត្រៃ ថែមទាំងបាត្រមួយទៀត។

ង១- សម្ភារៈក្នុងមួយត្រៃមាន :

១- ចីវរ១ : ក្រណាត់ទំហំ ២.៨០ម ឬ៣ម ឬ១.៨០ × ១.៩០ម

២- សង្ឃាដី១ : ក្រណាត់ពីរជាន់ទំហំដូចចីពរដែរ

៣- ស្បង់១ : ក្រណាត់ ២.៨០ម × ០.៨០ម

៤- ហង្សក១ (អង្សក)

៥- វត្តពន្ធចង្កេះ ឬខ្សែក្រវ៉ាត់១

៦- វត្តពន្ធទ្រូង ឬក្រណាត់ក្រវាត់ចង្កេះពីក្រៅ១

៧- ចង់យាម១

ង២- សម្ភារៈក្នុងមួយលៀង :

១- ចីពរមួយ

២- ស្បង់មួយ

៣- ហង្សកមួយ

៤- វត្តពន្ធចង្កេះ

ក្រៅពីសម្ភារៈដូចបានរៀបរាប់ខាងលើ ទាយកទាយិកាអាចបន្ថែមសម្ភារៈផ្សេងៗតាមចិត្តសទ្ធាជ្រះថ្លារបស់ខ្លួនដូចជា បាត្រ ចានស្រាក់ ចាន ឆ្នាំង កំសៀវ កន្ត្រៃ កន្ទេល ខ្នើយ គ្រែ សៀវភៅ ប៊ិច...

ច-កម្មវិធីបុណ្យ:ទាយកទាយិកាអ្នកផ្តើមបុណ្យត្រូវជ្រើសរើសថ្ងៃណាមួយក្នុងចន្លោះថ្ងៃ១រោជខែអស្សុជដល់ថ្ងៃ១៥កើតខែកត្តិក។

-ថ្ងៃទី១ វេលារសៀលជួបជុំពុទ្ធបរិស័ទ ព្រះសង្ឃចម្រើនព្រះបរិត្ត និងស្តាប់ធម៌ទេសនា ដែលធ្វើឡើងនៅតាមផ្ទះរបស់ទាយកទាយិកាអ្នកផ្តើមបុណ្យ ឬនៅក្នុងទីវត្តតែម្តងចំពោះកឋិនណា ដែលពុទ្ធបរិស័ទចំណុះជើងវត្តនាំធ្វើរួមគ្នា ។

-ថ្ងៃទី២ ពេលព្រឹកដង្ហែកឋិនទានចូលវត្ត ។ អ្នកផ្ដើមបុណ្យទូលត្រៃ ទូលលៀង និងកាន់សម្ភារៈផ្សេងៗទៀត ដោយមានទាំងវង់ភ្លេងឆៃយ៉ាំ ឬភ្លេងពិណពាទ្យកំដរបរិយាកាស ទៅជាមួយផង ។ ក្រោយចូលដល់ក្នុងទីវត្តហើយត្រៃនិងសម្ភារៈកឋិន ត្រូវតំកល់ទុកនៅទីកន្លែងមួយដ៏សមគួរ ។

បន្តមកទៀត ឧបាសកឧបាសិកាជើងវត្ត ប្រគេនចង្ហាន់ថ្ងៃត្រង់ដល់ព្រះសង្ឃ និងអញ្ជើញភ្ញៀវជិតឆ្ងាយពិសាភោជនាហារ ។ លុះចប់ពិធីនេះហើយ ទាយក ទាយិកា ឧបាសក ឧបាសិកា ទាំងអស់គ្នាដង្ហែត្រៃ ព្រមទាំងសម្ភារៈកឋិនប្រទក្សិណព្រះវិហារបីជុំរួចហើយទើបចូលទៅក្នុងព្រះវិហារនមស្ការព្រះរតនត្រ័យរួចវេរអង្គកឋិនចំពោះព្រះសង្ឃ ។

ឆ- សារៈសំខាន់បុណ្យកឋិន : បុណ្យកឋិនមានសារៈសំខាន់ក្នុងការឧបត្ថម្ភដល់ព្រះសង្ឃ នៅតាមទីវត្តអារាមនីមួយៗ ដើម្បីទ្រទ្រង់ព្រះពុទ្ធសាសនា ឱ្យមានភវភាពរៀងរហូត និងចំពោះពុទ្ធបរិស័ទទាំងឡាយអនុមោទនា ទទួលយកកុសលផលបុណ្យរបស់ខ្លួន ។ បច្ច័យដែលជាសទ្ធាជ្រះថ្លារបស់ទាយក ទាយិកា និងពុទ្ធបរិស័ទ ទាំងអស់ក្នុងពិធីកឋិននេះ សម្រាប់យកទៅកសាងព្រះវិហារ កុដិ សាលា... ដែលជាផលប្រយោជន៍នៃព្រះពុទ្ធសាសនា ។ មិនតែប៉ុណ្ណោះ នាពេលសព្វថ្ងៃនេះ បច្ច័យបុណ្យកឋិននៅតាមវត្តអារាមនីមួយៗ ក្រៅពីការសាងសង់សំណង់ពុទ្ធចក្រ ក៏នៅបានយកទៅកសាងសំណង់អាណាចក្រផងដែរ ដើម្បីជាគុណប្រយោជន៍ដល់សង្គមជាតិ។

ដូចនេះ បុណ្យកឋិនក៏បានក្លាយទៅជាបុណ្យប្រពៃណីមួយ ដូចជាបុណ្យដទៃៗទៀតដែរ ដែលជនជាតិខ្មែរយើងនិយមធ្វើរៀងរាល់ឆ្នាំ មិនដែលខកខានឡើយ ។

---

មគ្គុទ្ទេសក៍វប្បធម៌ទូទៅ- បណ្ឌិតសាស្ត្រាចារ្យ អ៊ីវ ចុង

## កើតជាមនុស្សនេះ ( ភាគគតិ )

« កើតជាមនុស្សនេះ បញ្ហាច្រើនម្លេះ ចោទជាប់គ្មានឃ្លាត
ដោះមួយរួចទៅ នៅសល់ដប់ទៀត កើតឡើងព្រោងព្រាត
ស្រាយមិនចេះអស់។
មានរឿងក្រពះ ចោទធ្ងន់ពេកណាស់ ត្រូវតែប្រឹងដោះ
ស្រាយចេញឲ្យរួច មុនគេបង្អស់ ទើបរួចរណ្ដោះ
ពីទុក្ខធំបាន។
ប៉ុន្តែមនុស្សនេះ ចិត្តមិនដែលចេះ ស្កប់ត្រឹមបាត់ឃ្លាន
វានៅបញ្ហា លោភលន់ធ្វើមាន ប្រមូលធនធាន
មកគរឱ្យស្កុក។
មានរឿងចង់ថ្កើង កេរ្តិ៍ឈ្មោះលេចឡើង លាន់ឮពេញស្រុក
ចង់ឱ្យគេស្គាល់ មានមាត់មានមុខ ចង់រក្សាទុក
កេរ្តិ៍ឈ្មោះយូរយារ។
មានរឿងកំហូច របិលរប៉ូច ចង់ផ្ដាប់តណ្ហា
ដោយសង្គមមនុស្ស បណ្ដុះប្រាថ្នា ឱ្យមនុស្សត្រូវការ
មិនដែលចេះស្កប់។
មានអ្វីៗទៀត ចិត្តចេះតែឆ្លៀត ចង់បានមិនចប់
បង្កើតជាទុក្ខ គ្មានបានសុខស្ងប់ គ្មានទីបញ្ចប់
ព្រោះកើតជាមនុស្ស។... »

## ល្បើកចាបស្រុកនិងចាបព្រៃ

កាលនោះមានចាបស្រុកនិងចាបព្រៃដើររកស៊ីដោយពួកជារៀងរាល់ថ្ងៃ។ខាងចាបស្រុកមានមេបាប្រាមប្រដៅថា៖ បើរកស៊ីកុំជជែកឈ្លោះគ្នា ឱ្យព្នមាត់គឹកកងឡើយ ឱ្យប្រយ័ត្នខ្លួន បើព្រានគេវាយលប់ត្រូវបបួលគ្នាខំាហើរទូលលប់នោះឱ្យរបើក ដើម្បីនឹងឱ្យរស់រួចជីវិត។

ពួកចាបស្រុកលុះតាមដំបូន្មានមេបាប្រដៅតែងដើររកស៊ីទៅបានរួចជីវិតតែរៀងៗមក។ មានកាលថ្ងៃមួយពួកចាបស្រុកនិងពួកចាបព្រៃហើរចេញទៅរកស៊ីប្រទះហ្វូងគ្នានៅដើមត្រែងមួយគុម្ព។ ពួកចាបព្រៃទុំនៅខាងក្រោម ពួកចានស្រុកទុំនៅខាងលើ ក៏បាក់មែកត្រែងពីលើមកត្រូវក្បាលពួកចាបព្រៃ។

ចាបព្រៃនិយាយទៅកាន់ចាបស្រុកថា៖

ហេតុអីក៏កាច់មែកត្រែងទម្លាក់មកឱ្យត្រូវក្បាលពួកយើង ?

ចាបស្រុកក៏បានប្រាប់ទៅចាបព្រៃវិញថា៖

យើងមិនបានកាច់មែកត្រែងឱ្យបាក់ត្រូវអ្នកឯងទេ គឺមែកត្រែងវាបាក់ឯងធ្លាក់មកទេតើ។ ពួកចាបព្រៃជាពួកឥតដំបូន្មាន មិនពិចារណាឱ្យឃើញខុសត្រូវ ក៏បបួលគ្នាបង្កហេតុបង្កើតជាជម្លោះនឹងពួកចាបស្រុក ព្នមាត់ជាគឹកកងរំពងឡើង។ ពួកព្រានបានព្នមាត់ចាបនៅគុម្ពត្រែងនោះច្រើនក៏យកលប់ទៅវាយត្រូវទាំងអស់គ្នា។ចាបទាំងពីរពួកនេះបានត្រូវលប់ហើយក៏នៅតែឈ្លោះគ្នាទៀត។

ចាបស្រុកពោលទៅកាន់ចាបព្រៃថា៖

បើពួកឯងគ្រាន់បើ ហេតុម្ដេចក៏មិនបម្រះឱ្យរួចពីលប់ទៅ។

ចាបព្រៃក៏ពោលមករកចាបស្រុកវិញថា៖

បើពួកឯងគ្រាន់បើ ហេតុម្ដេចក៏មិនបម្រះឱ្យរួចពីលប់នេះទៅ។ ចាបទាំងពីរពួកបានតែបញ្ជូនពាក្យឱ្យគ្នាទៅវិញទៅមក មិនគិតបម្រះឱ្យរួចជីវិតសោះ។ កំពុងតែឈ្លោះគ្នា ស្រាប់តែព្រានក្រសោបលប់ឡើងចាប់បានចាបទាំងអស់ក៏ពិឃាតក្ស័យអស់ទៅ។



ប្រាសាទភ្នំដា



រមណីយដ្ឋានប្រាសាទភ្នំបាណន់